ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Ministry of Labour and Vocational Training

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៩៣/២៥ ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌវិនិច្ឆ័យផ្តល់ពានរង្វាន់សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ប្រចាំឆ្នាំ២០២៥ សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ ៣៤២/២៣ ក.ប/ប្រ.ក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងាររៀបចំយន្តការវាយតម្លៃសហគ្រាសមួយ ជាសហគមន៍សុខសាន្តមួយ
- បានឃើញប្រកាសលេខ ៣៩៤/២៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការកំណត់លក្ខណវិនិច្ឆ័យសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

### ប្រការ១ .- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌអាទិភាពឱ្យសហគ្រាស គ្រឹះស្ថានអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមលក្ខណវិនិច្ឆ័យចំនួន ៨ ចំណុច ដូចមានចែងក្នុងប្រការ៣ នៃប្រកាសលេខ ៣៩៤/២៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការកំណត់លក្ខណវិនិច្ឆ័យសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ។ ដើម្បីទទួលបានពានរង្វាន់ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" សហគ្រាស គ្រឹះស្ថានត្រូវបំពេញតាមអនុលោមភាពចំនួន ៨ ដែលមានចែងចាប់ពីប្រការ២ ដល់ប្រការ៩ នៃប្រកាសនេះ។

### ប្រការ២ .- អនុលោមភាពនៃលក្ខខណ្ឌការងារ

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃលក្ខខណ្ឌការងារ សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

ក. បែបបទស្តីពីសហគ្រាស

១. មានចុះឈ្មោះបង្កើតគណនីសហគ្រាស ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS)
២. មានសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស
៣. មានសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក(ចូល-ចេញ)
៤. មានសៀវភៅបើកប្រាក់ឬបញ្ជីប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ
៥. មានបទបញ្ជាផ្ទៃក្នុងសហគ្រាស
៦. មានការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក
៧. បានធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស គ្រឹះស្ថាន និងលេខទូរសព្ទទំនាក់ទំនង
៨. បានអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

ខ. លក្ខខណ្ឌទូទៅនៃការងារ

១. ផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗដល់កម្មករនិយោជិតបានត្រឹមត្រូវ
២. ឱ្យកម្មករនិយោជិតធ្វើការត្រឹមត្រូវតាមថិរវេលាកំណត់ដោយច្បាប់
៣. ផ្តល់ការឈប់សម្រាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបានត្រឹមត្រូវ
៤. ផ្តល់ការឈប់សម្រាកបុណ្យដោយមានប្រាក់ឈ្នួលតាមប្រកាសរបស់ក្រសួង
៥. ផ្តល់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលបានត្រឹមត្រូវ
៦. បានអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះចាប់ពី៣ខែឡើង បានចេញពីធ្វើការមុន ចំនួន ១៥នាទី
៧. ផ្តល់ការឈប់សម្រាកលំហែមាតុភាពបានត្រឹមត្រូវ
៨. គ្មានការរើសអើង និងការងារដោយបង្ខំ។

### ប្រការ៣ .- អនុលោមភាពនៃការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

១. គ្មានប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
២. គ្មានប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុពី ១២ឆ្នាំ ទៅក្រោម ១៥ឆ្នាំ
៣. មានការអនុញ្ញាតឱ្យប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុពី ១៥ឆ្នាំ ទៅក្រោម ១៨ឆ្នាំ ត្រឹមត្រូវ
៤. អនុវត្តលក្ខខណ្ឌការងារ និងលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ របស់កម្មករនិយោជិតវ័យក្មេងបានត្រឹមត្រូវ។



ញ

## ប្រការ៤ ._ អនុលោមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

**ក. យន្តការបង្ការ ទប់ស្កាត់វិវាទការងារ និងកិច្ចសន្ទនាសង្គម**

១. បានអនុញ្ញាតឱ្យប្រតិភូបុគ្គលិកក្នុងការអនុវត្តតួនាទីរបស់ខ្លួន និងផ្តល់ពេលវេលា ២ម៉ោងក្នុងមួយសប្តាហ៍ សម្រាប់បំពេញតួនាទីរបស់ខ្លួន

២. ទទួលយកសំណូមពររបស់កម្មករនិយោជិតពីប្រតិភូបុគ្គលិក ដើម្បីដោះស្រាយឱ្យបានទាន់ពេលវេលា

៣. មានបុគ្គលិកទទួលបន្ទុកផ្នែករដ្ឋបាលដែលទទួលបានការបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីវិទ្យាស្ថានជាតិការងារ។

**ខ. យន្តការដោះស្រាយវិវាទការងាររបស់សហគ្រាស គ្រឹះស្ថាន**

១. មានយន្តការនៃការដោះស្រាយវិវាទនៅថ្នាក់សហគ្រាស គ្រឹះស្ថាន

២. បានសហការគ្នាល្អដោយភាគីទាំងពីរបាននាំយកវិវាទដែលមិនស្រុះស្រួលគ្នានៅថ្នាក់សហគ្រាស គ្រឹះស្ថាន មកដោះស្រាយបន្តនៅថ្នាក់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣. បានអនុវត្តតាមនីតិវិធីនៃការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល

៤. បានអនុវត្តស្របតាមនីតិវិធីច្បាប់ក្នុងការធ្វើកូដកម្ម ឬឡុកអៅ។

## ប្រការ៥ ._ អនុលោមភាពនៃលក្ខខណ្ឌស្តីពីសុវត្ថិភាព និងសុខភាពការងារ

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាព នៃលក្ខខណ្ឌស្តីពីសុវត្ថិភាព និងសុខភាពការងារ សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

**ក. ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារនៅសហគ្រាស គ្រឹះស្ថាន**

១. មានគណៈកម្មការ ឬក្រុមការងារសុវត្ថិភាព និងសុខភាពការងារ

២. មានការបណ្តុះបណ្តាលដល់ប្រតិភូបុគ្គលិក ប្រធានក្រុម ប្រធានផ្នែក និងកម្មករនិយោជិតអំពីវិធានការសុវត្ថិភាព និងសុខភាពការងារ

៣. មានគណៈកម្មការ ឬក្រុមការងារអេដស៍ និងគ្រឿងញៀនប្រចាំសហគ្រាស គ្រឹះស្ថាន

៤. គ្មានការផលិត ការធ្វើជំនួញ ឬការប្រើប្រាស់សារធាតុញៀនខុសច្បាប់នៅក្នុងសហគ្រាស គ្រឹះស្ថាន

៥. មានរបាយការណ៍វាយតម្លៃស្តីពីការអនុវត្តលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ។

**ខ. ផ្នែកសុខភាពការងាររបស់កម្មករនិយោជិត**

១. មានពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ/បរទេសមុនពេលចូលធ្វើការត្រឹមត្រូវ

២. មានការផ្តល់ភេសជ្ជៈអនាម័យបានគ្រប់គ្រាន់ និងត្រឹមត្រូវ

៣. មានបង្គន់អនាម័យបានគ្រប់គ្រាន់ និងត្រឹមត្រូវ

៤. មានវិធានសុវត្ថិភាពស្តីពីការប្រើប្រាស់សារធាតុគីមី សារធាតុដែលមានគ្រោះថ្នាក់ និងសារធាតុពុលបានត្រឹមត្រូវ

៥. មានទីតាំងស្តុកសារធាតុគីមី សារធាតុដែលមានគ្រោះថ្នាក់ និងសារធាតុពុលបានត្រឹមត្រូវ

៦. មានអត្រាគ្រោះថ្នាក់ការងារក្រោម ១០ភាគរយ នៃកម្មករនិយោជិតសរុប។



ញ

គ. ផ្នែកសេវាពេទ្យសហគ្រាស

១. មានប្រអប់សង្គ្រោះត្រឹមត្រូវ
២. មានបន្ទប់រុំរបួសត្រឹមត្រូវ
៣. មានរៀបចំគិលានដ្ឋានត្រឹមត្រូវ។

ឃ. ផ្នែកសុវត្ថិភាពការងារក្នុងអគារ

១. មានប្រព័ន្ធបញ្ចេញ បញ្ចូលខ្យល់នៅក្នុងអគារសមស្រប
២. មានច្រកចេញចូលក្នុងអគារផលិតកម្ម និងប៉ុស្តិ៍ការងារត្រឹមត្រូវ
៣. មានការបណ្តុះបណ្តាលអំពីនីតិវិធីពេលមានអាសន្នបានត្រឹមត្រូវ
៤. មានសញ្ញាការ/សញ្ញាសម្គាល់សុវត្ថិភាព និងសុខភាពការងារ និងចរាចរផ្ទៃក្នុងអគារបានត្រឹមត្រូវ
៥. មានការទុកដាក់សម្ភារប្រកបដោយសណ្តាប់ធ្នាប់
៦. មានសម្ភារ និងបរិក្ខារការពារអគ្គិភ័យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
៧. មានការប្រើប្រាស់ឡចំហាយត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
៨. មានការរៀបចំប្រព័ន្ធបណ្តាញខ្សែចរន្តអគ្គិសនីត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស
៩. មានកម្រិតពន្លឺ សំឡេង ធូលី និងកម្តៅសមស្រប។

ង. ផ្នែកគ្រឿងម៉ាស៊ីនដែលបង្កគ្រោះថ្នាក់

១. មានទីតាំងទុកដាក់គ្រឿងម៉ាស៊ីនប្រកបដោយសុវត្ថិភាពត្រឹមត្រូវ
២. មានបំពាក់ឧបករណ៍ការពារសុវត្ថិភាព ឬប្រព័ន្ធការពារដោយស្វ័យប្រវត្តិត្រឹមត្រូវ
៣. មានអ្នកទទួលខុសត្រូវគ្រឿងម៉ាស៊ីនត្រឹមត្រូវ
៤. មានការថែទាំគ្រឿងម៉ាស៊ីនជាប្រចាំត្រឹមត្រូវ។

## ប្រការ៦ .- អនុលោមភាពនៃរបបសន្តិសុខសង្គម

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃរបបសន្តិសុខសង្គម សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

១. បានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាននៅបេឡាជាតិសន្តិសុខសង្គម
២. បានចុះបញ្ជិកាកម្មករនិយោជិតនៅបេឡាជាតិសន្តិសុខសង្គមត្រឹមត្រូវ
៣. បានបង់ភាគទានឱ្យកម្មករនិយោជិតផ្នែកហានិភ័យការងារត្រឹមត្រូវ
៤. បានបង់ភាគទានឱ្យកម្មករនិយោជិតផ្នែកថែទាំសុខភាពត្រឹមត្រូវ
៥. បានបង់ភាគទានផ្នែកសោធនត្រឹមត្រូវ។

## ប្រការ៧ .- អនុលោមភាពនៃការប្រើប្រាស់កម្មករនិយោជិតជាជនពិការ

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃការប្រើប្រាស់កម្មករនិយោជិតជាជនពិការ សហគ្រាស គ្រឹះស្ថាន បានទទួលយកកម្មករនិយោជិតជាជនពិការឱ្យចូលបម្រើការងារ យ៉ាងតិច ១ភាគរយ នៃចំនួនកម្មករនិយោជិតសរុប ឬបានបង់ប្រាក់ភាគទានចំនួន ៤០ភាគរយ នៃប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតក្នុងមួយខែ សម្រាប់កម្មករនិយោជិតជាជនពិការមួយនាក់។

## ប្រការ៨ .- អនុលោមភាពនៃការអនុវត្តកម្មវិធីលើកកម្ពស់ផលិតភាពការងារ

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃការអនុវត្តកម្មវិធីលើកកម្ពស់ផលិតភាពការងារ សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១. មានការហ្វឹកហ្វឺនកូនជាង ឬបង់ពន្ធអាករជំនួសបានត្រឹមត្រូវ ឬ

២. មានទទួលយកអ្នកហាត់ការ ឬកម្មសិក្សាការីបានត្រឹមត្រូវ ឬ

៣. មានការបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling) និងការបង្កើនជំនាញ (Upskilling)។

## ប្រការ៩ .- អនុលោមភាពនៃការអនុវត្តកម្មវិធីទទួលខុសត្រូវសង្គម

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពនៃការអនុវត្តកម្មវិធីទទួលខុសត្រូវសង្គម សហគ្រាស គ្រឹះស្ថាន ត្រូវបំពេញ និងអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

១. បានចូលរួមគាំទ្រដល់ដំណើរការទារកដ្ឋានសហគមន៍

២. បានបង្កើតកម្មវិធីលើកទឹកចិត្តដល់កម្មករនិយោជិតក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ពិធីបុណ្យភ្ជុំបិណ្ឌ និងទិវាពលកម្មអន្តរជាតិ

៣. បានសហការ និងផ្តល់ឱកាសឱ្យកម្មករនិយោជិតចូលរួមក្នុងកម្មវិធីសំណេះសំណាល កម្មវិធីលើកកម្ពស់វប្បធម៌ ប្រពៃណី និងសិក្ខាសាលាផ្លូវការនានារបស់រាជរដ្ឋាភិបាល ក្រសួង និងអាជ្ញាធរ។

## ប្រការ១០ .- ការវាយតម្លៃផ្តល់វិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាព

គណៈកម្មការវាយតម្លៃ និងជ្រើសរើសសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ត្រូវផ្អែកលើរបាយការណ៍អធិការកិច្ចការងារប្រចាំឆ្នាំនីមួយៗ និងរបាយការណ៍ផ្សេងៗទៀតដែលផ្តល់ជូនដោយសហគ្រាស គ្រឹះស្ថាន ដើម្បីផ្តល់វិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាពដូចមានចែងក្នុងប្រការ២ ដល់ប្រការ៩ នៃប្រកាសនេះ។

## ប្រការ១១ .- ការផ្តល់ពានរង្វាន់សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ

គណៈកម្មការវាយតម្លៃ និងជ្រើសរើសសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ត្រូវផ្អែកលើវិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាពដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ ដើម្បីជ្រើសរើស និងផ្តល់ពានរង្វាន់ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" ទៅតាមប្រភេទចំណាត់ថ្នាក់លេខ១ លេខ២ និងលេខ៣។

## ប្រការ១២ .- កាលបរិច្ឆេទប្រគល់ពានរង្វាន់

ការប្រគល់ពានរង្វាន់ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" ត្រូវបានកំណត់នៅថ្ងៃរៀបចំខួបអនុស្សាវរីយ៍នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ប្រចាំឆ្នាំនីមួយៗ។

## ប្រការ១៣ .- ការអនុវត្តប្រកាស

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃបេឡាជាតិសន្តិសុខសង្គម ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១០កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ